# តក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម
# PATENTS

# INTRODUCTION

# ប្រវត្តិ:

មុនសង្គ្រាមលោកលើកទី១ ការការពារកម្មសិទ្ធិឧស្សាហកម្ម ជាពិសេសតកកកម្ម ពុំមានប្រសិទ្ធភាព

# INTRODUCTION

# ប្រវត្តិ:

អនុសញ្ញាអន្តរជាតិត្រូវបានបង្កើតឡើង៖

- អនុសញ្ញា ទីក្រុងប៉ារីស ១៨៨៣

ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម

# INTRODUCTION

# ប្រវត្តិ:

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៦៧ អនុសញ្ញាអន្តរជាតិមួយត្រូវបានបង្កើតឡើង ដែលមានឈ្មោះថា អនុសញ្ញាទីក្រុង STOCKHOLM ស្តីពីការបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក

# INTRODUCTION

## ផលប្រយោជន៍៖

- ➢ លើកទឹកចិត្តក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង បច្ចេកវិជ្ជា
- ➢ ផ្ទេរបច្ចេកវិជ្ជា
- ➢ ទាក់ទាញអ្នកវិនិយោគក្នុង និងក្រៅប្រទេស
- ➢ បង្កើតទីផ្សារការងារក្នុងស្រុក

# អ្វីជាប្រកាសនីយបត្រតក្កកម្ម?

គឺជាវិញ្ញាបនបត្រដែលរដ្ឋផ្តល់ទៅឲ្យតក្កករ ដើម្បីការពារតក្កកម្ម (ម.៣.១)

ន័យទូលាយ ជាឯកសារដែលចេញឲ្យដោយការិយាល័យរបស់រដ្ឋាភិបាលណាមួយ ឬ ការិយាល័យសម្រាប់តំបន់ណាមួយ ដែលដើរតួនាទីក្នុងនាមរដ្ឋច្រើន ហើយវាអាស្រ័យទៅតាមការដាក់ពាក្យសុំ។

# អ្វីខ្លះអាចជាតក្កកម្ម?

- ទូរស័ព្ទ
- ម៉ាស៊ីនបូមធូលី
- ម៉ាស៊ីនកុំព្យូទ័រ
- ឱសថ
- ថ្នាំងអ៊ុត
- ម៉ាស៊ីន


MAYBACH






LIT



# តក្កកម្មដែលទទួលការការពារ

- កម្មវត្ថុស្របច្បាប់ (SUBJECT MATTER)
- ត្រូវតែថ្មី (NOVELTY)
- មានជំហាននៃការរកឃើញថ្មី (INVENTIVE STEP)
- អាចអនុវត្តបានក្នុងឧស្សាហកម្ម (INDUSTRIAL APPLICABLE) (មាត្រា៥)

# ការមិនរំលោភសិទ្ធិលើបង្កើតទម្រង់

តក្កកម្មត្រូវតែស្របច្បាប់ ហើយវាត្រូវតែជាការបង្កើតថ្មីពីគំនិតបញ្ញារបស់មនុស្ស ផលិតចេញមកត្រូវតែស្របច្បាប់ និង ដែលវាមានផលប្រយោជន៍សម្រាប់ការប្រើប្រាស់ ជាពិសេសអាចយកទៅធ្វើអាជីវកម្មបាន និងមិនត្រូវបានផាត់ចេញពីការការពារ ឬ មិនត្រូវបានច្បាប់ហាមឃាត់ (ឧ.រកឃើញឧបករណ៍កែឆ្នៃ ឬ ផលិតគ្រឿងញៀន)

# ត្រូវបានដាក់ចេញពីការការពារ

១. ការរកឃើញនូវទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា

២. គម្រោងការ ក្បួន ឬ វិធីសាស្ត្រសម្រាប់ជំនួញ  ឬ សម្រាប់ល្បែងកំសាន្ត

៣. វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្ស ឬ សត្វដោយការវះកាត់ ឬ ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគដែលបានអនុវត្តលើរាងកាយមនុស្ស ឬ សត្វ

៤. ផលិតផលឱសថដូចមានចែងក្នុងមាត្រា ១៣៦ (កំពុងធ្វើវិសោធនកម្ម)

៥. រុក្ខជាតិ ឬ សត្វដែលមិនមែនជាមីក្រូសរីរាង្គ

៦. ប្រភេទផ្សេងៗ នៃប្រភេទរុក្ខជាតិណាមួយ។ (មាត្រា៤)

# ថ្មី NOVELTY

សំដៅដល់ការបង្កើតថ្មីទាំងឡាយណាដែលមិនធ្លាប់មានពីមុន មិនធ្លាប់ត្រូវបានគេរកឃើញពីមុនមកសោះ ឬ មិនធ្លាប់ត្រូវបានគេអនុវត្តពីមុនមក ហើយរួមទាំងមិនដែលធ្លាប់មានអ្នកណាម្នាក់បានដឹង ឬ បានឮពីការបង្កើតថ្មីនេះពីមុនមកសោះឡើយ នៅទូទាំងពិភពលោក (ម.៦)

# ចំណាំ

ទោះបីជាបានដឹង ឮ ដល់សាធារណៈជនរួចហើយក៏ដោយ ក៏ត្រូវបានគេចាត់ទុកថាជាតក្កកម្មមួយថ្មីដែរ ប្រសិនបើការដឹងឮពីតក្កកម្មនោះ បានកើតឡើងក្នុងរយៈពេល ១២ខែ មុនកាលចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាពនៃការចុះបញ្ជី (មាត្រា៦.ក)

# ជំហានថៃការរកឃើញថ្មី

តក្កកម្មនោះ មិនអាចឲ្យបុគ្គលដែលមានកម្រិតធម្មតាក្នុងជំនាញអាចយល់ដឹងបាន ហើយវាទាមទារឲ្យបុគ្គលដែល មានជំនាញកម្រិតខ្ពស់ទើបអាចយល់ដឹងបាន ពីដំណើរការរបស់តក្កកម្មនោះ

# ជំហាននៃការរកឃើញថ្មី (ត)

ប្រសិនបើតក្កកម្ម ដែលទើបរកឃើញនោះ អាចឲ្យបុគ្គលដែលមានកម្រិតជំនាញធម្មតា អាចយល់ដឹងបាន មានន័យថា តក្កកម្មនោះ មិនមានជំហាននៃការរកឃើញថ្មីទេ ព្រោះវាបានបាត់បង់នូវភាពអច្ឆារ្យ ឬលក្ខណៈពិសេសរបស់វាហើយ។ (មាត្រា ៧)

# អាចអនុវត្តបានក្នុងឧស្សាហកម្ម

តក្កកម្មនោះ ត្រូវតែអាចយកទៅផលិត ឬ អាចប្រើប្រាស់នៅក្នុងប្រភេទណាមួយនៃឧស្សាហកម្ម។ មានន័យថា អាចយកតក្កកម្មនោះទៅធ្វើអាជីវកម្ម លក់ ឬ ជួល បាន (ទាញយកប្រយោជន៍ពីតក្កកម្មនោះបាន) (មាត្រា ៨)

# ចំណាំ

តក្កកម្មណាដែលធ្វើអាជីវកម្ម ពាណិជ្ជកម្ម

-ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ សីលធម៌

-មិនការពារជីវិត ឬ សុខភាពរបស់មនុស្ស សត្វ ឬ រុក្ខជាតិ

-ធ្វើឲ្យខូចបរិស្ថានធ្ងន់ធ្ងរ ឬ

-ត្រូវបានច្បាប់ហាមឃាត់

មិនត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្មឲ្យទេ។

(មាត្រា ៩)

# ការដាក់ពាក្យសុំ

ការដាក់ពាក្យស្នើសុំ ប្រកាសនីយបត្រតក្កកម្ម គឺ ជាសំណុំលិខិតទាំងឡាយដែលបានដាក់ស្នើទៅអាជ្ញាធរ ដែលមានសមត្ថកិច្ចក្នុងការចេញនូវប្រកាសនីយបត្រតក្កកម្ម។

# ការដាក់ពាក្យសុំ (ត)

<u>គោលការណ៍ចុះបញ្ជីមុន</u> <u>FIRST-TO-FILE POLICY</u>:

A PATENT WILL BE GRANTED TO THE FIRST PERSON TO FILE A PATENT APPLICATION. THIS IS CALLED THE 'FIRST-TO-FILE' SYSTEM. THAT IS WHY THE **FILING DATE** OF AN APPLICATION FOR PATENT IS VERY IMPORTANT

# ការដាក់ពាក្យសុំ (ត)

ការស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវបានចែកចេញជាពីរផ្នែកគឺ ប្រកាសនីយបត្រតក្កកម្មជាតិ និងការប្រកាសនីយបត្រតក្កកម្មបរទេស។

# ការដាក់ពាក្យសុំ (ត)

ប្រកាសនីយបត្រតក្កកម្មជាតិ: រាល់ការរកឃើញថ្មីទាំងឡាយណា ដែលបានរកឃើញនៅក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំ

ប្រកាសនីយបត្រតក្កកម្មបរទេស: តក្កកម្មដែលបានរកឃើញមិនស្ថិតនៅក្នុងប្រទេស ដែលបានដាក់ពាក្យស្នើសុំ